# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

PHNOM PENH WATER SUPPLY AUTHORITY
រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ
លេខៈ ២២៦៣.ន.ល

ថ្ងៃព្រហ ១៣រោច ខែកត្ដិក ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
រាជធានីភ្នំពេញ, ថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០២៤

**ជម្រាបមក**

**លោកស្រីប្រធានក្រុមហ៊ុន អេ.ស៊ី.អ៊ី.អេស អ៊ិនជាសស្ទ្រៀស ឯ.ក**

**កម្មវត្ថុ** : ការសម្រេចជ្រើសរើស និងប្រគល់កិច្ចសន្យាស្តីពីការផ្គត់ផ្គង់គ្រឿងបន្លាស់ប្រព័ន្ធមេកានិច(ផែនការកែតម្រូវ-ឆ្នាំ២០២៤)។

**យោង** : កំណត់ហេតុបើកឯកសារដេញថ្លៃ ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២៤ និងកំណត់ហេតុវាយតម្លៃប្រគល់កិច្ចសន្យា ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០២៤ របស់គណៈកម្មាធិការលទ្ធកម្មរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ សូមលោកស្រីប្រធានក្រុមហ៊ុនជ្រាបថា: ដោយផ្អែកលើកំណត់ហេតុវាយតម្លៃរបស់គណៈកម្មាធិការលទ្ធកម្ម រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញសម្រេចជ្រើសរើស និងប្រគល់កិច្ចសន្យាជូន **ក្រុមហ៊ុន អេ.ស៊ី.អ៊ី.អេស អ៊ិនជាសស្ទ្រៀស ឯ.ក** ដើម្បីធ្វើការផ្គត់ផ្គង់គ្រឿងបន្លាស់ប្រព័ន្ធមេកានិច (ផែនការកែតម្រូវ-ឆ្នាំ២០២៤) ជូនរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ក្នុងតម្លៃទឹកប្រាក់សរុបចំនួន **២៣៩,៨៣០,០០០រៀល (ពីររយសាមសិបប្រាំបួនលានប្រាំបីរយសាមសិបពាន់រៀលគត់)** ជាតម្លៃកិច្ចសន្យា។

សូម លោកស្រីប្រធានក្រុមហ៊ុន ទទួលយកនូវការរាប់អានដ៏ស្មោះពីខ្ញុំ។

**ជ. គណៈកម្មាធិការលទ្ធកម្ម**
**អនុប្រធាន**

**ឌុំ ផល្លា**

ចម្លងជូនៈ
-ក្រុមហ៊ុន អ៊ីអេសអេសភី ស៊ីលូសិន ឯ.ក
-ក្រុមហ៊ុន អេស.អិម.អូ.អិន ត្រេឌីង ឯ.ក
-ឯកសារ-កាលប្បវត្តិ